**ធម្មទេសនារបស់លោកអភិបាល អូលីវីយេ**
**អភិបូជាសប្តាហ៍ទី២នៃរដូវរង់ចាំ នៅព្រះសហគមន៍សន្តិម៉ារីញញឹម**
**ចំការឪឡឹក ថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០២០**

# ចូររៀបចំផ្លូវថ្វាយព្រះអម្ចាស់

**អត្ថបទទី១៖ អេសាយ ៤០,១-៥.៩-១១**

ចូរជួយសម្រាលទុក្ខប្រជាជនរបស់យើង កុំបង្អង់ឡើយ!។ អស ៤០,១

**អត្ថបទទី២៖ ពេត្រុសទី២ ៣,៨-១៤**

ព្រះអង្គសម្តែងព្រះហឫទ័យអត់ធ្មត់ចំពោះបងប្អូន ព្រោះទ្រង់មិនសព្វព្រះហឫទ័យឲ្យនរណាម្នាក់ត្រូវវិនាសទេ គឺទ្រង់សព្វព្រះហឫទ័យឲ្យមនុស្សលោកគ្រប់ៗរូបកែប្រែចិត្តគំនិតវិញ។ ២ សល ៣,៩

**ដំណឹងល្អ៖ ម៉ាកុស ១,១-៨**

ខ្ញុំបានធ្វើពិធីជ្រមុជឲ្យអ្នករាល់គ្នាក្នុងទឹក រីឯលោកវិញ លោកនឹងធ្វើពិធីជ្រមុជឲ្យអ្នករាល់គ្នាក្នុងព្រះវិញ្ញាណដ៏វិសុទ្ធ។ មក ១,៨

បងប្អូនជាទីស្រឡាញ់!

ចូររៀបចំផ្លូវថ្វាយទៅព្រះជាម្ចាស់ ថ្ងៃនេះជាសប្តាហ៍ទីពីរនៃរដូវរង់ចាំ ជាពេលវេលាដើម្បីរៀបចំចិត្តគំនិត ដើម្បីថ្វាយផ្លូវ ដើម្បីថ្វាយខ្លួន ដើម្បីថ្វាយជីវិត ទៅព្រះជាម្ចាស់ដែលកំពុងយាងមក។ នៅក្នុងពេលវេលាដែលជំងឺកូវីដ១៩ កំពុងរាតត្បាតចូលនៅក្នុងសហគមន៍ បានណែនាំឲ្យយើងភ័យខ្លាច ណែនាំឲ្យយើងព្រួយបារម្ភ ជាពិសេសណែនាំឲ្យយើងសោកស្តាយ ដោយសាររដូវរង់ចាំជារដូវអបអរសាទរព្រះយេស៊ូដែលកំពុងយាងមក ជារដូវនៃអំណរសប្បាយ ប៉ុន្តែយើងកំពុងពិបាកដោយសារកន្លែងមួយចំនួនយើងឥតមានអភិបូជា និងកន្លែងដែលមានអភិបូជាក៏មានគ្នាតិចដែរ។ ប៉ុន្តែ យើងនៅតែបន្តមានសេចក្តីសង្ឃឹម យ៉ាងតិចយើងមានសេចក្តីសង្ឃឹមនៅក្នុងដួងចិត្ត សេចក្តីសង្ឃឹមដោយយើងខិតខំរៀបចំអ្វីដែលយើងអាចរៀបចំបានតាមកន្លែងនីមួយៗ ដើម្បីឲ្យវត្តមានរបស់ព្រះយេស៊ូដែលកំពុងយាងមក ពោរពេញដោយអត្ថន័យនៅក្នុងឆ្នាំ២០២០នេះ។

ថ្ងៃទី០៦ ខែធ្នូ ជាថ្ងៃដែលយើងនឹករលឹកដល់សន្ត នីកូឡា ដែលជាលោកអភិបាលម្នាក់នៅក្នុងសតវត្សទ៍ទី៣។ មានរឿងនិទានមួយ ដែលណែនាំឲ្យយើងគិតពិចារណាអំពីជីវិតរបស់យើងដែរ។ មានថ្ងៃមួយ មានកូនក្មេងបីនាក់កំពុងធ្វើដំណើរនៅក្នុងរដូវរងានិងឆាច់ងងឹត ពេលគេកំពុងធ្វើដំណើរព្រះអាទិត្យបានលិចគេរកមិនឃើញផ្លូវ។ ក្រោយមកគេបានឃើញមានផ្ទះមួយដែលមានភ្លើង ជារបស់បុរសម្នាក់ឈ្មោះសិលាខ្មៅជាអ្នកលក់សាច់។ ក្មេងទាំងបីនាក់បានទទួលស្វាគមន៍ដោយសិលាខ្មៅយ៉ាងកក់ក្តៅ ក្រោមមកសិលាខ្មៅបានសម្លាប់ក្មេងទាំងបីនាក់នោះ

ហើយប្រឡាក់អំបិល ដើម្បីទុកធ្វើសាច់ហូបពេលក្រោយ។ នៅយប់ដដែលនោះមាន លោកអភិបាល នីកូឡា បានធ្វើដំណើរកាត់តាមផ្ទះរបស់សិលាខ្មៅនេះ។ លោកអភិបាល បានសួរទៅលោកសិលាខ្មៅថា **"មុននេះបន្តិចមានកូនក្មេងបីនាក់ដែលចូលនៅក្នុងផ្ទះសិលាឯងមែនទេ?"** ពេលនោះគាត់បានលុតជង្គង់ទទួលសារភាពថា គាត់បានសម្លាប់កូនក្មេងទាំងបីនេះហើយ។ លោក នីកូឡា បានទៅដល់កន្លែងដែលសិលាខ្មៅដាក់សាច់កូនក្មេងនោះ ត្រៀបដៃនិងធ្វើសញ្ញាឈើឆ្កាងបីដង កូនក្មេងទាំងបីមានជីវិតសាជាថ្មី។ លោកអភិបាល នីកូឡា បាននាំសិលាខ្មៅទៅតាមភូមិនីមួយៗ ដើម្បីប្រមូលកូនក្មេងទាំងអស់នៅតាមភូមិ។ ក្មេងណាដែលបានធ្វើអំពើល្អបានទទួលកាដូពីលោកអភិបាល នីកូឡា កូនក្មេងណាដែលធ្វើអំពើអាក្រក់ត្រូវទទួលពិន័យពីលោកសិលាខ្មៅ។ ប្រពៃណីនេះនៅមាននៅទ្វីបអឺរ៉ុបរហូតមកដល់សព្វថ្ងៃ ជាពិសេសនៅតាមសាលារៀន។ អត្ថបទដែលយើងបានស្តាប់ពីសប្តាហ៍មុន នៅខាងស្តាំដៃព្រះមហាក្សត្រមានសត្វចៀម ជាសញ្ញានៃមនុស្សដែលខិតខំធ្វើអំពើល្អ នៅខាងឆ្វេងដៃមានសត្វពពែ ជាសញ្ញានៃមនុស្សដែលធ្វើអំពើអាក្រក់។ ជីវិតរបស់យើងនៅក្នុងរដូវរង់ចាំ ជាពេលវេលាដើម្បីគិត **តើខ្ញុំត្រូវធ្វើដូចម្តេចដើម្បីដើរតាមផ្លូវយ៉ាងល្អ ដើម្បីរៀបចំចិត្តគំនិតទទួលស្វាគមន៍ព្រះយេស៊ូ?** យើងត្រូវការពិចារណាអំពីរបៀបដែលយើងត្រូវកែប្រែចិត្តគំនិត ដើម្បីមានចរិតជាគ្រីស្តបរិស័ទ ជាប្រជាជនរបស់ព្រះជាម្ចាស់ ដែលចេះស្រឡាញ់ព្រះអង្គពិតមែន។

នៅក្នុងការកែប្រែចិត្តគំនិតមានបីចំណុចដ៏សំខាន់គឺៈ

**ចំណុចទីមួយ ឲ្យយើងគោរព កោតខ្លាច ស្រឡាញ់ព្រះជាម្ចាស់** នេះជាប្រភពនៃអ្វីៗទាំងអស់ ប្រសិនបើយើងគោរព កោតខ្លាច ស្រឡាញ់ព្រះជាម្ចាស់ ណែនាំឲ្យយើងមានកម្លាំងនៅក្នុងចិត្ត ណែនាំឲ្យយើងមានសេចក្តីស្រឡាញ់នៅក្នុងចិត្តរបស់យើងពិតមែន។ តែបើយើងមិនគោរព កោតខ្លាច ស្រឡាញ់ព្រះជាម្ចាស់ទេនោះ យើងគ្មានពន្លឺដើម្បីធ្វើអំពើល្អ ហើយយើងក៏គ្មានកម្លាំងដើម្បីធ្វើអំពើល្អដែរ។ សិលាខ្មៅ ប្រហែលគាត់មិនកោតខ្លាចព្រះជាម្ចាស់ទេ ទើបគាត់ហ៊ានសម្លាប់ក្មេងទាំងបីនាក់ទុកធ្វើជាសាច់សម្រាប់បរិភោគ។ ប្រសិនបើយើងគោរព កោតខ្លាច ស្រឡាញ់ព្រះជាម្ចាស់ នៅក្នុងជីវិតរបស់យើង យើងយកចិត្តទុកដាក់ដើម្បីធ្វើអំពើល្អ យើងយកចិត្តទុកដាក់ដើម្បីបង្ហាញសេចក្តីស្រឡាញ់ពិតៗ យើងយកចិត្តទុកដាក់ដើម្បីបង្កើតបរិយាកាសពោរពេញដោយធម៌មេត្តាករុណាពិតមែន។ ដោយសារយើងចង់ឲ្យព្រះជាម្ចាស់សប្បាយចិត្ត យើងចង់ឲ្យព្រះជាម្ចាស់ស្រឡាញ់យើង យើងចង់ឲ្យជីវិតរបស់យើងនៅថ្ងៃអនាគតពោរពេញដោយសេចក្តីសុខ ដោយជឿព្រះជាម្ចាស់ណែនាំឲ្យយើងឡើងស្ថានបរមសុខ។ ដូច្នេះ យើងជាកូនក្មេងក្តី យើងជាយុវជនក្តី យើងជាមនុស្សពេញវ័យក្តី ឲ្យយើងគោរព កោតខ្លាច ស្រឡាញ់ព្រះជាម្ចាស់ជាប្រភពនៃកម្លាំង ដើម្បីឲ្យយើងរស់នៅតាមសេចក្តីស្រឡាញ់ដែលយើងទទួលពីព្រះជាម្ចាស់។

**ចំណុចទីពីរ ឲ្យយើងមានចិត្តអាណិតមេត្តាដល់បងប្អូនឯទៀតៗ** សង្គមរបស់យើងជូនកាលភ្លេចនឹកឃើញដល់អ្នកតូចតាច ដល់មនុស្សដែលយើងគិតថាគ្មានតម្លៃ។ ប្រសិនបើយើងមានចិត្តអាណិតមេត្តា យើងអាចចាប់អារម្មណ៍អំពីអ្នកតូចតាច មានន័យថាយើងដាក់ចិត្តអស់ពីសមត្ថភាពដើម្បីស្រឡាញ់គេ ស្រឡាញ់អ្នកជំងឺម្នាក់ ស្រឡាញ់អ្នកក្រីក្រម្នាក់ ស្រឡាញ់មនុស្សដែលអស់សង្ឃឹមម្នាក់...។ មិនមែនតែចាប់អារម្មណ៍ល្មមៗ ប៉ុន្តែចាប់អារម្មណ៍ដោយមានចិត្តអាណិតមេត្តា មានន័យថាយើងស្រឡាញ់គេជ្រៅណាស់។ អ្នកដែលមានស្នេហា នៅពេលគេស្រឡាញ់ដៃគូគេ មិនទាន់ល្មមទេដើម្បីទៅមុខ ប៉ុន្តែពេលគេនិយាយថាអាណិតគាត់ហើយមានន័យថាគេអាចទៅមុខបាន គេអាចរៀបការនឹងគ្នាបាន។ នៅក្នុងជីវិតរបស់យើង មិនមែនតែសេចក្តីស្រឡាញ់ល្មមទេប៉ុន្តែអាណិតមេត្តា ប្រសិនបើយើងជាក្រុមសង្គហៈដែលជួយចាស់ជរានៅក្នុងឱកាសបុណ្យព្រះយេស៊ូប្រសូត ប្រសិនបើយើងចេះតែជួយដោយមានអង្ករតិចតួច ឬគ្រឿងឧបភោគបរិភោគបន្តិចបន្តួច តែឥតចាប់អារម្មណ៍អំពីគាត់មានប្រយោជន៍អ្វី។ ព្រះជាម្ចាស់ណែនាំឲ្យយើងមានចិត្តអាណិតមេត្តា មានន័យថាស្រឡាញ់ដ៏ពិតប្រាកដ។ ឲ្យយើងពិចារណា នៅក្នុងរដូវរង់ចាំនេះ ដើម្បីធ្វើដំណើរជាមួយព្រះជាម្ចាស់ ដើម្បីមានចរិតថ្មី គោរព កោតខ្លាច ស្រឡាញ់ព្រះជាម្ចាស់ មានចិត្តអាណិតមេត្តាដ៏ពិតប្រាកដដល់បងប្អូនឯទៀតៗ។

**ចំណុចទីបី ឲ្យយើងមានចិត្តស្មោះត្រង់ចំពោះព្រះជាម្ចាស់ ស្មោះត្រង់ចំពោះបងប្អូនឯទៀតៗ និងស្មោះនៅក្នុងសង្គមជានិច្ច។** ដោយសារ នៅពេលដែលយើងមិនស្មោះត្រង់ វាអាចមានឥទ្ធិពលអាក្រក់ដល់បងប្អូនឯទៀតៗយ៉ាងច្រើន និងអាចត្រលប់មកដល់ខ្លួនយើងវិញដែរ។ ដូចអនុសាសន៍របស់សម្តេចតេជោ ហ៊ុន សែន ដែលបានស្នើឲ្យប្រជាជនទាំងអស់ដែលពាក់ព័ន្ធនឹងជំងឺកូវីដ១៩ ឲ្យមានចិត្តស្មោះត្រង់ ដោយមិននិយាយកុហក ដោយឆ្លើយពិត ប្រសិនបើយើងនិយាយមិនពិតនោះណែនាំឲ្យជំងឺកូវីដ១៩ រាតត្បាតចូលសហគមន៍កាន់តែខ្លាំងឡើងៗ។ ដូច្នេះ ឲ្យយើងថែរក្សាចិត្តស្មោះត្រង់ ដើម្បីត្រៀមចិត្តគំនិតនៅពេលសន្ត នីកូឡា មកជួបយើង យើងនឹងបានរង្វាន់ពីគាត់ កុំឲ្យសិលាខ្មៅមកដាក់ទោសយើង ដោយសារយើងបានធ្វើខុស ឆ្ងាយពីព្រះហឫទ័យស្រឡាញ់របស់ព្រះជាម្ចាស់។

យើងអធិដ្ឋាន ដើម្បីឲ្យជីវិតរបស់យើងភ្ជាប់ជាមួយព្រះអង្គ ដោយយកចិត្តទុកដាក់គិតពិចារណាជាពិសេសនៅក្នុងរដូវរង់ចាំនេះ។ ទោះបីយើងចូលអភិបូជាមិនបាន ទោះបីយើងជួបជុំគ្នាមិនបាន ប៉ុន្តែយើងជួបជាមួយព្រះជាម្ចាស់បានគ្រប់ទីកន្លែងដែលយើងនៅ។ ប្រសិនបើយើងជាគ្រួសារកាតូលិក យើងអាចជួបជុំជាលក្ខណៈគ្រួសារជាមួយកូន យើងអានអត្ថបទគម្ពីរ យើងអធិដ្ឋាន ដើម្បីរៀបចំចិត្តគំនិតស្វាគមន៍ព្រះយេស៊ូដែលកំពុងយាងមក។ អាម៉ែន៕